ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា

440 N. BROAD STREET – 2nd Floor, Suite 206
PHILADELPHIA, PENNSYLVANIA 19130

ការិយាល័យផ្តល់ជំនួយពិសេស | **ការបម្រើផ្នែកសុខភាពនៅសាលា**

(២១៥) ៤០០-៦០០៤

ទូរសារ៖ (២១៥) ៤០០០-៤១៧៣

ការបង្រៀនសិស្សនៅផ្ទះ

ជូនចំពោះមាតាបិតា/អាណាព្យាបាល៖ ថ្ងៃខែ៖ _____________

ការបង្រៀនសិស្សនៅផ្ទះ បានបង្កើតឡើងដើម្បីតម្រូវតាមសេចក្តីត្រូវការនៃការអប់រំរបស់សិស្ស នៅពេលដែលសិស្សអវត្តមានបណ្តោះអាសន្ន ដើម្បីឲ្យពួកគេអាចទទួលបានជោគជ័យនៅក្នុងកម្មវិធីសិក្សា នៅពេលពួកគេត្រឡប់មកសាលាវិញ។ ការបង្រៀនសិស្សនៅផ្ទះ មិនអាចធ្វើឡើងក្នុងគោលបំណង ឬការអះអាងថា ជាវិធីបង្រៀនពេញលក្ខណៈតាមកម្មវិធីសិក្សា និងមិនអាចផ្តល់ពិន្ទុឲ្យបានគ្រប់គ្រាន់សម្រាប់ឡើងថ្នាក់ បានទេ។ ការបង្រៀនសិស្សនៅផ្ទះ មិនអាចជំនួសការមករៀននៅសាលាបានទេ។ ការប្រងៀននៅផ្ទះគម្បីយកមកប្រើជាវិធីចុងក្រោយបង្អស់ ក្រោយពេលប្រើវិធី និង/ឬ កម្មវិធីផ្សេងៗទៀត (ឧ. រៀនកន្លះថ្ងៃ ដាក់កិច្ចការឲ្យធ្វើ (wok packets) ។ល។) អស់ហើយ។

- ការបង្រៀនសិស្សនៅផ្ទះគឺជាការបម្រើដែលក្រសួងអាចផ្តល់ឲ្យនៅពេលដែលសិស្សអវត្តមានបណ្តោះអាសន្ន ដោយសារមានបញ្ហាសុខភាពធ្ងន់ធ្ងរ យ៉ាងហោចណាស់ ៤ សប្តាហ៍ និងមិនអាចហួសពី ៣ខែ ទៅតាមការតម្រូវរបស់ក្រសួងអប់រំនៃរដ្ឋផែនស៊ីវេនញា។
- គេអាចផ្តល់ការបង្រៀនសិស្សនៅផ្ទះចន្លោះៗពេល ទៅតាមអវត្តមានដោយមានមូលហេតុរយៈពេលខ្លី ប៉ុន្តែញឹកញាប់ ដោយសារបញ្ហាសុខភាពកាន់តែធ្ងន់ធ្ងរឡើងៗ (ដោយមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីអ្នកផ្តល់សេវាសុខភាព)។ សិស្សត្រូវត្រឡប់មករៀនវិញនៅពេលភាពធ្ងន់ធ្ងរនោះបានថយចុះ។ ការយល់ព្រមសម្រាប់ ការបង្រៀននៅផ្ទះចន្លោះៗពេល អាចអនុញ្ញាតឲ្យមិនហួសពីមួយ (១) ឆ្នាំសិក្សា ហើយនឹងផុតកំណត់នៅចុងឆ្នាំសិក្សា។

ដើម្បីដាក់ពាក្យសុំ ការបង្រៀនសិស្សដែលមិនអាចចេញពីផ្ទះដោយសារពិការភាព មាតាបិតា/អាណាព្យាបាល របស់សិស្ស ត្រូវតែមានលិខិតបញ្ជូន របស់វេជ្ជបណ្ឌិត បំពេញ ចុះហត្ថលេខា ដោយវេជ្ជបណ្ឌិតរបស់សិស្ស ហើយប្រគល់ឲ្យគិលានុបដ្ឋាកសាលាវិញ។ **ក្រសួងប្រហែលជាមិនទទួលលិខិតបញ្ជូនរបស់វេជ្ជបណ្ឌិតទេ បើសិនជាលិខិតនោះមិនបានពន្យល់ពីមូលហេតុនៃអវត្តមានរបស់សិស្ស។ មាតាបិតា/អាណាព្យាបាល មានសិទ្ធិមិនព្រមបង្ហាញព័ត៌មាននៃសុខភាព តែទោះជាយ៉ាងនេះក្តី ការមិនព្រមបង្ហាញព័ត៌មាននៃសុខភាព អាចនាំឲ្យគេបញ្ចប់ការបង្រៀននៅផ្ទះ។**
បើសិនជាស្ថានភាពសុខភាពរបស់កូនលោកអ្នក តម្រូវឲ្យមានការបង្រៀននៅផ្ទះលើសពីបី (៣) ខែ លោកអ្នកត្រូវតែផ្តល់ លិខិតបញ្ជូនថ្មីពីវេជ្ជបណ្ឌិត មុនពេលលិខិតដាក់ពាក្យសុំលើកទីមួយផុតកំណត់។ បើសិនជាមិនផ្តល់ លិខិតបញ្ជូនថ្មីពីវេជ្ជបណ្ឌិត ទាន់ពេលទេ ការបង្រៀននៅផ្ទះ របស់កូនលោកអ្នក នឹងត្រូវបញ្ឈប់ ហើយគេនឹងកត់សម្គាល់ថាកូនលោកអ្នកអវត្តមាន។

ជោគជ័យនៃការបង្រៀននៅផ្ទះ និងការរីកចម្រើនរបស់កូនលោកអ្នក គឺយោងទៅលើការសហការគ្នារៀបផែនការ ដែលមាន កូនរបស់លោកអ្នក គ្រូបង្រៀននៅផ្ទះ និង មាតាបិតា/អាណាព្យាបាល។ នៅពេលដែលគេយល់ព្រមដល់ការបង្រៀននៅផ្ទះរួចហើយ មាតាបិតា/អាណាព្យាបាល ត្រូវតែប្រកាន់ខ្ជាប់នូវកិច្ចព្រមព្រៀងដូចតទៅនេះ៖
- ផ្តល់បន្ទប់ដែល ស្អាត ស្ងាត់ស្ងៀម មានពន្លឺ និងមានសីតុណ្ហភាពល្អ សម្រាប់ គ្រូ និង សិស្ស។
- មនុស្សពេញវ័យដែលមានការទទួលខុសត្រូវ ត្រូវមានវត្តមាននៅផ្ទះ ក្នុងរយៈពេលបង្រៀន។
- សិស្សត្រូវស្លៀកពាក់ឲ្យបានសមរម្យ ហើយត្រៀមខ្លួនជាស្រេចសម្រាប់ការបង្ហាត់បង្រៀន នៅពេលគ្រូដែលបង្រៀននៅផ្ទះ មកដល់។
- ត្រូវតែអនុញ្ញាតឲ្យ គ្រូ និងសិស្ស បង្រៀន និងរៀន ដោយគ្មានការរំខាន ដូចជា ទូរទស្សន៍ វិទ្យុ សត្វចិញ្ចឹម និងក្មេងៗផ្សេងទៀត នៅពេល បង្ហាត់បង្រៀន និង រៀនសូត្រ។
- ត្រូវជំរាបគ្រូឲ្យដឹង នៅម៉ោង ៨:៣០ ព្រឹក បើសិនជាសិស្សឈឺធ្ងន់ មិនអាចបង្រៀនបាន ឬ បើសិនជាអ្នកណាម្នាក់ដែលនៅក្នុងផ្ទះមានជម្ងឺដែលអាចឆ្លង។
- ចុះហត្ថលេខាលើទំព័រកត់ម៉ោងរបស់គ្រូ នៅពេលចប់ការបង្ហាត់បង្រៀនម្តងៗ។
- រៀបចំការណាត់ជួបជាមួយវេជ្ជបណ្ឌិត ការព្យាបាល ។ល។ កុំឲ្យជាន់ពេលជាមួយម៉ោងបង្ហាត់បង្រៀន បើសិនជាអាចធ្វើទៅបាន។
- បើមិនធ្វើតាមល័ក្ខខ័ណ្ឌទាំងអស់ខាងលើនេះ អាចបណ្តាលឲ្យគេបញ្ឈប់ ការបង្រៀននៅផ្ទះ។

■ *ខ្ញុំបានអាន ហើយយល់ព្រម តាមល័ក្ខខ័ណ្ឌទាំងអស់សម្រាប់ ការបង្រៀនសិស្សនៅផ្ទះ សម្រាប់កូនខ្ញុំ។ ខ្ញុំនឹងផ្តល់បរិយាកាស សម្រាប់ការបង្ហាត់បង្រៀនដែលពេញចិត្ត ដើម្បីឲ្យកូនខ្ញុំអាចរៀនសូត្របានល្អបំផុត។*

____ _____________________________

ហត្ថលេខារបស់ **មាតាបិតា/អាណាព្យាបាល** / SIGNATURE OF PARENT/GUARDIAN *ថ្ងៃខែ* / DATE

____ _____________________________

អាស័យដ្ឋាន / ADDRESS លេខទូរស័ព្ទ / TELEPHONE NUMBER

ឈ្មោះសិស្ស៖ /Student Name______________________________ *ឈ្មោះសាលា*/School*៖* ____________________________________ *ថ្នាក់ទី៖* /Grade__________

- **ឲ្យមួយច្បាប់ទៅ មាតាបិតា/អាណាព្យាបាល / One (1) copy to Parent/Guardian**
- **ទុកមួយច្បាប់ក្នុងសំណុំឯកសារនៅសាលាសម្រាប់ សិស្សដែលមិនអាចចេញពីផ្ទះ / One (1) copy to be kept in the homebound student's file at school**
- **ឲ្យមួយច្បាប់ទៅ គ្រូដែលបង្រៀននៅផ្ទះដោយសារពិការភាព / One (1) copy to the homebound teacher**